**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧៩៦ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ មិនា ឆ្នាំ ២០១៣

**ប្រកាស**
**ស្តីពី**
**កម្រៃធានាឥណទាន នៃគម្រោងមូលនិធិធានាឥណទាន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ/បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០/អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៩/អនក្រ/បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៩០/អនក្រ/បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិធានាឥណទាន

- បានឃើញប្រកាសលេខ ១០៨០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងមូលនិធិធានាឥណទាន
- បានឃើញប្រកាសលេខ ១៣៥ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងមូលនិធិធានាឥណទាន (អ.ម.ធ.ឥ.)
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១:** ប្រកាសនេះមានគោលបំណងកំណត់ពីកម្រៃធានាឥណទាន ដែលទទួលបានពីការធានាមួយផ្នែកលើកញ្ចប់កម្ចីឥណទាន របស់ស្ថាប័នហិរញ្ញវត្ថុចូលរួម ក្រោមគម្រោងមូលនិធិធានាឥណទាន។

**ប្រការ ២:** និយមន័យ នៃវាក្យស័ព្ទ ដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម:

"**ស្ថាប័នហិរញ្ញវត្ថុចូលរួម**" សំដៅដល់ ធនាគារពាណិជ្ជ ឬគ្រឹះស្ថានហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងទៀត ដែលបានចុះបញ្ជីត្រឹមត្រូវ ដោយអនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ហើយបានចុះកិច្ចព្រមព្រៀងជាមួយអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងមូលនិធិធានាឥណទាន (អ.ម.ធ.ឥ.) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាអង្គភាពអនុវត្តគម្រោងមូលនិធិធានាឥណទាន ដើម្បីទទួលបានការធានាមួយផ្នែកលើកញ្ចប់កម្ចីឥណទានរបស់ខ្លួន ។

"**កម្ចីឥណទាន**" សំដៅដល់ កម្ចីឥណទានណា ដែលស្ថាប័នហិរញ្ញវត្ថុចូលរួមបានផ្តល់ឲ្យអ្នកខ្ចី ហើយទទួលបានការធានាមួយផ្នែកពីគម្រោងមូលនិធិធានាឥណទាន ។

"**កញ្ចប់កម្ចីឥណទាន**" សំដៅដល់ កម្ចីឥណទាននីមួយៗ ដែលត្រូវបានបញ្ចូលគ្នាដោយស្ថាប័នហិរញ្ញវត្ថុចូលរួម ទៅក្នុងកញ្ចប់កម្ចីឥណទានរួមមួយ ហើយស្នើសុំការធានាមួយផ្នែកលើកញ្ចប់កម្ចីឥណទាននោះ មកគម្រោងមូលនិធិធានាឥណទាន ។

"**កម្រិតកំណត់ឥណទាន (Facility Limit)**" គឺជាកម្រិតសម្រាប់កំណត់ទំហំទឹកប្រាក់ នៃកម្ចីឥណទានសរុបរបស់ស្ថាប័នហិរញ្ញវត្ថុចូលរួម ដែល អ.ម.ធ.ឥ. អាចធានាបានក្នុងមួយពេល ។

**ប្រការ ៣:** អនុញ្ញាតឲ្យ អ.ម.ធ.ឥ. យកកម្រៃធានាឥណទាន ពីការធានាមួយផ្នែកលើកញ្ចប់កម្ចីឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុចូលរួម ។

**ប្រការ ៤:** កម្រៃធានាឥណទាន ត្រូវបានកំណត់ ដូចខាងក្រោម៖

ក. មូលដ្ឋានទឹកប្រាក់សម្រាប់គិតកម្រៃធានាឥណទាន គឺជាចំនួនទឹកប្រាក់កម្ចីឥណទាននីមួយៗ ដែលបានផ្តល់ការធានាមួយផ្នែកដោយ អ.ម.ធ.ឥ. ។

ខ. កម្រៃធានាឥណទានត្រូវគិតតាមអត្រាកម្រៃ ០,៥% ក្នុងមួយឆ្នាំ ដែលត្រូវយកទៅចែកជាមួយនឹងចំនួន ៣៦០ ដើម្បីបានអត្រាកម្រៃក្នុងមួយថ្ងៃ ។

គ. កម្រៃធានាឥណទានត្រូវគណនាដោយយកចំនួនទឹកប្រាក់កម្ចីឥណទាននីមួយៗ គុណនឹងចំនួន ថ្ងៃកំណត់សងនៃកម្ចីឥណទាននោះ ហើយគុណនឹងអត្រាកម្រៃប្រចាំថ្ងៃ ដូចមានចែងក្នុងចំណុច "ខ" នៃប្រការនេះ។

ឃ. ក្នុងរយៈពេល ០៦ ខែ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងធានាឥណទាន ប្រសិនបើកញ្ចប់កម្ចីឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុចូលរួម នៅមានកម្រិតទាបជាង ១៥% នៃកម្រិតកំណត់ឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុចូលរួម នោះ អ.ម.ធ.ឥ. មានសិទ្ធិយកកម្រៃបន្ថែមតាមអត្រា ០,២៥% លើចំណែកកម្រិតកំណត់ឥណទាន ដែលមិនបានប្រើប្រាស់ដោយស្ថាប័នហិរញ្ញវត្ថុចូលរួម ។

**ប្រការ ៥:** អ.ម.ធ.ឥ. មានសិទ្ធិពេញលេញ និងស្របច្បាប់ ក្នុងការមិនផ្តល់ការធានាលើកម្ចីឥណទានណាមួយរបស់ស្ថាប័នហិរញ្ញវត្ថុចូលរួម ក្នុងករណីដែលស្ថាប័នហិរញ្ញវត្ថុចូលរួមនោះ មិនបានបង់កម្រៃធានាឥណទាន ដូចមានចែងក្នុងប្រការ ៤ ឲ្យបានទាន់ពេលវេលា ពោលគឺក្នុងរយៈពេល ០២ សប្តាហ៍ គិតចាប់ពីថ្ងៃដែល អ.ម.ធ.ឥ. បានឯកភាពធានាលើកញ្ចប់កម្ចីឥណទាននោះ ។

**ប្រការ ៦:** ស្ថាប័នហិរញ្ញវត្ថុចូលរួម ត្រូវបង់កម្រៃធានាឥណទាន ដូចមានចែងក្នុងប្រការ ៤ ចូលគណនីឈ្មោះ Rice Sector Partial Credit Guarantee Fund ដែលមានលេខ 0000 0000 ៩៧៣៣ នៅធនាគារជាតិ នៃកម្ពុជា ។

**ប្រការ ៧:** ចំណូលបានមកពីកម្រៃធានាឥណទាន ត្រូវយកទៅប្រើប្រាស់សម្រាប់បង្កើនទុនមូលនិធិធានាឥណទាន ។ ក្នុងករណីចាំបាច់ អ.ម.ធ.ឥ. អាចស្នើសុំថវិកាមួយចំនួនពីមូលនិធិនេះ ដើម្បីទ្រទ្រង់ប្រតិបត្តិការរបស់ខ្លួន តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៨:** រាល់ការកែប្រែកម្រៃធានាឥណទាន ត្រូវធ្វើឡើងតាមរយៈប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ៩: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ១០: អគ្គលេខាធិការ នាយកគម្រោងមូលនិធិធានាឥណទាន នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក គ្រប់ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន:

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

-ធនាគារជាតិ នៃកម្ពុជា «ដើម្បីជូនជ្រាប»

-ដូចប្រការ១០ «ដើម្បីអនុវត្ត»

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ